# ការសម្ភាសរបស់អ៊ុំស្រី ក្រូច រ៉ន

កៈ អ្នកសម្ភាស ញ៉ែម លាភី ខៈ អ្នកត្រូវគេសម្ភាស ក្រូច រ៉ន

គៈ បងប្អូន ឃៈ កូន

## ការសង្ខេបរបស់អ៊ុំស្រី ក្រូច រ៉ន

អ៊ុំស្រីក្រូច រ៉ន គាត់ជាអ្នកស្រុកមកពីតាកែវ អ៊ុំស្រីត្រូវបានឪពុកស្លាប់ចោលតាំងពីគាត់នៅពេលក្មេងខ្លាំងណាស់ ហើយម្ដាយក៏ស្លាប់ចោលនៅពេលគាត់អាយុ៨ឆ្នាំទៀត ហើយគាត់ត្រូវរស់នៅដោយកំព្រាឪពុកម្ដាយ ហើយត្រូវដើរនៅជាមួយមីងមាគ្រប់កន្លែង ហើយគាត់ក៏បានទៅនៅបាត់ដំបង ហើយត្រពាំងលើកហើយបានមករស់នៅទន្លេបាទីវិញ។ បងប្អូនអ៊ុំស្រីដែលត្រូវបានព្រាត់ប្រាស់គ្នាមិនបានជួបហើយមានអ្នកខ្លះបាត់ខ្លួននៅក្នុងជំនាន់ប៉ុល ពត។អ៊ុំត្រូវបានបងប្អូនខាងឪពុកយកទៅនៅជាមួយព្រោះតែឪពុកបានផ្ដាំទៅបងប្អូនឱ្យជួយមើលកូន

គាត់។ នៅពេលក្នុងសង្គ្រាមប៉ុល ពតដែលធ្វើឱ្យជីវិតអ៊ុំមានការលំបាកខ្លាំង ហើយគាត់ក៏រៀបអាពាហ៍ពិពាហ៍នៅក្នុងកាលពេលជំនាន់ហ្នឹងដែរ ប៉ុល ពតបានរៀបចំការឱ្យគាត់ ហើយគាត់ក៏យកស្វាមីមួយហ្នឹងមកដល់សព្វថ្ងៃហើយមានកូន៩នាក់រស់នៅមកដល់សព្វថ្ងៃហ្នឹង។

កៈ សូមជម្រាបសួរអ៊ុំនាងខ្ញុំមានឈ្មោះ ញ៉ែម លាភីហើយនាងខ្ញុំសុំសម្ភាសអ៊ុំនៅក្នុងថ្ងៃនេះគឺនៅក្នុងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៨។ហើយការសម្ភាសនេះគឺនៅក្នុងខេត្តតាកែវ ស្រុកបាទីហើយសុំទោសអ៊ុំតើអ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខៈ ឈ្មោះក្រូច រ៉ន។ជីតាគេយកជីតាហី?

កៈ ចាសក្រូច រ៉ន។ ចុះមិនមែនឈ្មោះមុំ រ៉នទេអ៊ុំណោះ?

ខៈ មុំ រ៉ន ហ្នឹងអ្នកដាក់ឱ្យហ្នឹងចេះតែដាក់ឱ្យហ្នឹងណាស់។

កៈ នៅក្នុងសំបុត្រកំណើតគេចេះតែដាក់ឱ្យ?

ខៈ ហ្នឹងហើយ។

កៈ តាមពិតឈ្មោះក្រូច រ៉នទេ?

ខៈ ហ្នឹងហើយ។

កៈ ហើយអ៊ុំមានចាំថាអ៊ុំកើតនៅក្នុងថ្ងៃណាខែណាអីអត់អ៊ុំ?

ខៈ អត់ចាំ។

កៈ ចាសបើតាមនៅក្នុងសំបុត្រកំណើតគេថ្ងៃទី០២ ខែមករា ឆ្នាំ១៩៥៦។ហើយចុះអ៊ុំមានចាំទីកន្លែងកំណើតអត់?

ខៈ ចាសអូនឯងមើលគេដាក់ឱ្យយ៉ាងម៉េច?

កៈ ចាសនៅក្នុងសំបុត្រកំណើតគេដាក់ថានៅក្នុងភូមិថ្នល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ប្រទេសកម្ពុជា។

ខៈ ខ្ញុំដាក់នៅហ្នឹង។

កៈ កន្លែងហ្នឹងអត់ខុសទេអ៊ុំណោះ?ត្រឹមត្រូវតាមសំបុត្រកំណើតហ្នឹង?ចុះអ៊ុំសព្វថ្ងៃរស់នៅកន្លែងណាដែរអ៊ុំ?

ខៈ រស់នៅក្នុងភូមិថ្នល់ទក្សិណអូន។

កៈ ចាសនៅកន្លែងជាមួយស្រុកកំណើតហ្នឹងដែរ?

ខៈ ចាស!

ក៖ អ៊ុំតាំងពីតូចមកដល់ឥឡូវអត់មានដែលផ្លាស់ប្តូរទីលំនៅអីទេអ៊ុំណោះ?

ខ៖ អត់ទេ។

ក៖ ចាស!

ខ៖ ខ្ញុំធ្លាប់កាលពេលនៅតូចណាស់ ប្រហែលជា១ឆ្នាំ២ឆ្នាំហ្នឹងខ្ញុំទៅនៅបាត់ដំបងនោះ ដល់ពេលបានអាយុ១០ឆ្នាំបាននៅទីនេះវិញ។

ក៖ ចាសហើយម៉េចបានប្តូរទៅនៅណោះវិញអ៊ុំ?

ខ៖ តាមម៉ែនោះ។

ក៖ ចាស!

ខ៖ នៅបាត់ដំបង១០ឆ្នាំណាស់ ហ្នឹងហើយម៉ែគាត់ទៅតាមម៉ែគាត់នោះ។

ក៖ ហេតុអីគាត់ប្តូរទៅនៅណោះវិញអ៊ុំ?

ខ៖ មិនដឹងយ៉ាងម៉េចគាត់ហ្នុ៎...បើយើងនៅតូចៗយើងអត់សូវដឹងច្បាស់ណាស់។

ក៖ ចាសៗ!

ខ៖ ហ្នឹងហើយ។

ក៖ អ៊ុំមានចាំថាឆ្នាំអីឆ្នាំខ្មែរណាស់?

ខ៖ រកា។

ក៖ ឆ្នាំរកា។

ខ៖ ឆ្នាំរកាតែគ្រាន់តែយើងដឹងថាយើងឆ្នាំរកាយើងអត់ដឹងថាថ្ងៃអីខែអីណាស់។

ក៖
ចាសអ៊ុំតាំងពីតូចមកមានឈ្មោះហៅក្រៅអត់តាំងពីតូចមកគេមានឈ្មោះហៅងារក្រៅអីផ្សេងអីអញ្ចឹងណាស់?

ខ៖ ងារ ឈ្មោះថន។

ក៖ ឈ្មោះថន?អ្នកណាគេអ្នកដាក់ឱ្យអ៊ុំ?

ខ៖ មីងថនហ្នឹងណាស់ មីងថនពូម៉ែនោះពេលនៅជាមួយគាត់ចេះតែដាក់ឈ្មោះ។

ក៖ ឈ្មោះដាក់?

ខ៖ មិនមែនទេខ្ញុំនៅឯណោះណាស់ នៅឯស្រុកត្រពាំងលើកគេហៅថន ហើយដល់ពេលមកណេះមីងថនគាត់ឈ្មោះថនដែរគាត់ដាក់ឈ្មោះដាក់ងារ៉េនវិញទៅ។

គ៖ កាលពេលមុនឈ្មោះថនសោះ។

ខ៖ អើរ... បានដាក់ថនហ្នឹងណាស់។

គ៖ និយាយអញ្ចឹងបានដឹងណាស់។

ខ៖ នៅត្រពាំងលើកគេអត់ស្គាល់ឈ្មោះខ្ញុំថារ៉េន ស្គាល់តែថនទេ។

ក៖ ពេលមុនមកឈ្មោះថនទេ?

ខ៖ អើរ...ដល់ពេលគាត់...។

គ៖ ដល់ពេលមីងថនទៅដាក់រ៉េនវិញ?

ខ៖ អើរ...!

ក៖ ចាសទើបប្តូរ ចុះអ៊ុំអត់នៅជាមួយម្តាយបង្កើតទេអ៊ុំហោ?

ខ៖ នៅជាមួយគេតាំងពីអាយុ៨ឆ្នាំមក។

ក៖ ហ្ហ៎...កំព្រា?

ខ៖ ឪពុកស្លាប់តាំងពីចេះអង្គុយ ហ្អែងគិតមើល។

គ៖ គាត់ចាញ់ភីគាត់ទៅបាត់ដំបង។

ខ៖ គាត់ចាញ់ទៅបាត់ដំបងនោះ។

គ៖ ពោះធំលឺសូរម៉ែនិយាយ។

ក៖ ម្ដាយរបស់អ៊ុំគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះម៉វ។

ក៖ ឈ្មោះម៉វ?

ខ៖ មុំ ម៉វ។

ក៖ មុំ ម៉វ?ចុះឪពុកវិញអ៊ុំ?

ខ៖ ឪពុកតាមុំហ្នឹង។

ក៖ ចាសចុះម្ដាយ?

ខ៖ ម្ដាយឈ្មោះម៉វ។

ក៖ ម៉វ?

ខ៖ ម្ដាយបង្កើត ហា៎...។

ក៖ ចាស!

ខ៖ ម្ដាយបង្កើតឪពុកបង្កើតហ្នឹង មីងហ្នឹង។

ក៖ អ៊ុំមានដែលដឹងថាគាត់ អត់ដែលដឹងថាគាត់កើតនៅណាអីទេហី?នៅក្មេងពេកអត់ដឹង?

ខ៖ នៅក្មេងពេកអត់ដឹង។

ក៖ ពួកគាត់សុទ្ធតែស្លាប់អស់ហើយ??

ខ៖ ស្លាប់អស់ហើយ។

ក៖ ស្លាប់ដោយសារជម្ងឺអីគេឬក៏...?

ខ៖ គាត់ស្លាប់ទាស់ហ្នឹងណាស់ បើឪចាញ់។

ក៖ ហ្អ៎...!

ខ៖ ឪពុកចាញ់ម៉ែទាស់?

ក៖ ហើយអ៊ុំរស់នៅជាមួយគេទៅ?

ខ៖ រស់នៅជាមួយមីង។

ក៖ ចាស!

ខ៖ រស់ជាមួយមីង ជាមួយបងគិតទៅគ្រប់កន្លែង មុនដំបូងមីងថនរួចពីមីងថនមកនៅជាមួយមីងឡូ រួចពីមីឡូទៅនៅជាមួយបង រួចពេលមកនៅជាមួយបង ហ្នឹងហើយទៅនៅជាមួយពូខុន ពូខុនហើយពូខៃហើយបានធ្លាក់មកមីងវិញ។

ក៖ ចាស!

គ៖ គិតទៅច្រើនកន្លែងហើយនេះ។

ខ៖ ច្រើន ខ្ញុំកំព្រាឃើញទេ។

ក៖ ចាសហើយអ៊ុំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ខ៖ មានបងប្អូនទាំងអស់៣។

ក៖ ៣នាក់?

ខ៖ ស្លាប់អស់ហើយ។

ក៖ ស្លាបអស់ទាំងអស់?

ខ៖ ចាស!

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានទៅអ៊ុំ?

ខ៖ នេះបើម៉ែជាមួយគ្នាឪពុកជាមួយគ្នាមាន៣ណាស់។

ក៖ ចាស!

ខ៖ តែមានឪពុកដោយខ្លួនទៀតមាន២ទៀតប៉ុន្តែស្លាប់អស់ហើយ។

ក៖ ចាស!

ខ៖ ស្លាប់អស់ហើយ  ទាំងគ្នា៧នាក់ហ្នឹងហ្ន៎...មើល៧អីតែ៥នាក់ទេ។

គ៖ រៀបរាប់ឈ្មោះផង។

ខ៖ ថន ហា...វាឈ្មោះប៉ុកទេ ហើយស្ទីតមួយទៀត ធឹម ថុល ថុលធឹម។

ក៖ ពួកគាត់ស្លាប់ដោយសារអីគេអ៊ំ?

ខ៖ អាពត។

ក៖ អាពតសម្លាប់?

ខ៖ បងខ្ញុំឈ្មោះថននោះគាត់ឈឺ គាត់ឈឺណាស់។

ក៖ ចាស!

ខ៖ ឈឺគ្រុនក្តៅ ហើយធឹមនោះវាបាត់អាពតវ៉ៃចោល។

ក៖ កាលពេលពួកគាត់ស្លាប់អាយុប្រហែលប៉ុន្មានដែរ?

ខ៖ គាត់ស្លាប់៧៥អូន(១៩៧៥)គាត់ឆ្នាំមមែហា...។

ក៖ ចាស!

ខ៖ មមែបើនៅជិត៧០ហើយណាស់។

ក៖ ច្រើនដែរ។

ខ៖ ស្លាប់បើគិតមកដល់ឥឡូវជិត៥០ឆ្នាំហើយ ពេលឆ្នាំ៧៥(១៩៧៥)ហា...ស្លាប់។

ក៖ ចាស!

ខ៖ ស្លាប់អាពតយកវ៉ៃចោល។

ក៖ គ្រាន់តែអាពតចូលភ្លាមសម្លាប់ចោលភ្លាមតែម្តងមឹង?

ខ៖ គាត់នៅជាមួយសក្តិមួយសក្តិពីរណាស់។

ក៖ ហ្នឹងហើយ។

ខ៖ អញ្ចឹងគេគិតថាកូន ទំនងណាស់។

ក៖ ហ្ហ៎...!

ខ៖ ធឹមហ្នឹងដូចពូម៉នអញ្ចឹងណាស់ សក់រួញអង្គារ៍ជីរួញដូចគ្នាខ្ពស់ស្គមដូចគ្នា។

ក៖ ព្រោះខ្ញុំឮគេថា។

ខ៖ ឃើញមុខពូម៉នមុខដូចបងខ្ញុំបង្កើតអញ្ចឹងណាស់។

ក៖ ឱ្យតែអ្នកចេះគឺសម្លាប់ចោល។

ខ៖ ចាយកសុំធ្វើកូនណាស់។

ក៖ ហ៊ឺ...ស្តាយណាស់មឹង។

ខ៖ ហើយអញ្ចឹងគេថាកូនគេគេវ៉ៃចោលទាំងអស់ទៅ តាំងពីឆ្នាំ៧៧ (១៩៧៧) ពីឆ្នាំ៧៧ ៧៨ហ្នឹង(១៩៧៧ ១៩៧៨)ស្លាប់ហ្នឹងហើយ ព្រោះអីបែកភ្នំពេញសួរតាឈុំហ្នឹងគាត់ឃើញតាថាឃើញមានឃើញទេ?ថាហ៊ឺ...អញសួរជួបអ្នកណាគេទេ?អូនៗឯងជួបបងខ្ញុំបង្កើតហ្នឹងបែកភ្នំពេញមួយថ្ងៃហ្នឹង។

ក៖ ចាស!

ខ៖ ជួបថា អូនឯងដូចក្មួយអាម៉ន អាម៉នព្រោះមុខដូចគ្នាណាស់ បាទខ្ញុំហ្នឹងហើយកូនតាមុំនៅហនុមាណ។ណែ...ហើយចុះអូនឯងមិនដែលទៅលេងយាយនៅអូរបែកក្អម?គ្រាន់តែជួបខ្មោចតាខ្នុល

ស្គាល់ទេតាខ្ទុលយាយកាននេះណាស់ហើយតាឈូកហ្នឹង ជួបថ្ងៃហ្នឹងស្អែកឡើងគេវ៉ៃចូលភ្នំពេញណាស់ អាពតវ៉ៃចូលភ្នំពេញហ្នឹង ថាហ៊ី...ចាំស្អែកចាំមកលេងទទួលអាពតវ៉ៃចូលទៅហ្នឹង ហ្នឹងគេប្រាប់ខ្ញុំណាស់ ថាជួបទេតើ ថាស្អាតមើលអត់ស្គាល់ឯណា ថាកុំតែស្រដៀងមុខទេ ថាមុខដូចពូម៉ននណាស់។

គ៖ ព្រោះនៅជាមួយគេអ្នកមានអញ្ជឹងហើយ។

ខ៖ ហ្នឹងហើយ។ស្លាប់តាំងពេលហ្នឹងមកអាពតវ៉ៃចូលហ្នឹងណាស់ ហើយអាប្អូន២នាក់ក៏

អញ្ជឹងដែរ ក៏អាពតដែរ។

ក៖ ហើយអញ្ជឹងអ៊ុំសល់ប៉ុន្មាន?

ខ៖ សល់តែម្នាក់ឯងទេ។

ក៖ សល់តែម្នាក់ឯង?

ខ៖ ស្លាប់អស់៣ អស់៤ អស់ហើយ។

ក៖ និយាយទៅអ៊ុំអត់មានសល់អ្នកណាគេសោះ?

ខ៖ អត់នៅតែម្នាក់ឯង។

ក៖ ឪពុកម្ដាយបងប្អូនបង្កើតៗអស់រលីងហើយ?

ខ៖ អស់រលីង។

ក៖ សល់តែម្នាក់ឯង។

ខ៖ ម្នាក់ឯង។ចាសសល់តែក្មួយៗ ក្មួយបង្កើត អាពតសម្លាប់៣នាក់ហាំ...ប្រុសមួយស្រី២ហាំ...អញ្ជឹងអាពតសម្លាប់ហើយបែករហូតមកអូនឯងគិតមើលហ្ន៎...។

ក៖ ចាសដឹងតែស្លាប់ឬក៏បាត់ឈឹងហ្មងអ៊ុំ?

ខ៖ បាត់ឈឹងតែម្ដង ហ្អែងគិតមើល ជិត៤០ឆ្នាំហើយអត់មានដំណឹងផង សួរអត់លិចហាំ...។

គ៖ ដូចអ៊ុំរិនហ្អែង។

ខ៖ ព្រោះគេគេសុំធ្វើជាកូនបង្កើត។

ក៖ ចាស!

ខ៖ អញ្ចឹងវាថាយើងហ្នឹងជាប់ពាក់ពន្ធ័ហ្នឹង។

ក៖ ចាសស្តាយណាស់អ៊ុំនិយាយទៅឱ្យតែអ្នកចេះអ្នកពូកែអីគឺស្លាប់អស់ហើយជំនាន់ហ្នឹង។ចុះអ៊ុំកាលពេលគាត់ស្លាប់ហ្នឹងកាលអ៊ុំនៅពេលអាយុប៉ុន្មានដែរអ៊ុំពួកគាត់ស្លាប់?

ខ៖ បងស្លាប់ហេ?

ក៖ ហ្នឹងហើយ បងបងប្អូនបង្កើត?

ខ៖ បងស្លាប់អាយុ២០ជាងហើយ។

ក៖ ២០ជាង?

ខ៖ ២២ ២៣ ហើយបើបងនេះទើបស្លាប់គាត់ស្លាប់ទើបតែ១០ឆ្នាំនេះទេ។

ក៖ ចាស!

ខ៖ កាលយើងអាយុ៥០។

ក៖ អ៊ុំកាលពេលនៅក្មេងអ៊ុំធ្លាប់លេងអីគេជាមួយពួកគាត់ខ្លះទៅ?

ខ៖ អត់ទេអូន បែកគ្នាតើ។

ក៖ អត់ដែលបានលេងអីជាមួយគ្នាតាំងពីតូចមក?

ខ៖ អត់ បែកគ្នាតាំងពីម៉ែស្លាប់មកវាបានជួបគ្នាភាគតិចណាស់ វាអត់បានអី។

ក៖ ពួកគាត់ទៅនៅជាមួយគេផ្សេងៗដែរ?

ខ៖ ចាសនៅជាមួយគេផ្សេងៗដែរ។ ចាំមើលខ្ញុំនៅបាត់ដំបងអញ្ចឹងមួយទៀតទៅនៅក្រុងបាត់ដំបងមួយហើយខ្ញុំនៅជនបទ នៅស្ទឹងណាស់។

ក៖ ចាស!

ខ៖ មួយនៅបាត់ដំបង នៅក្រុងបាត់ដំបងណាស់។

ក៖ ចាស!

ខ៖ ហើយមួយទៀតឃ្វាលក្របីគេនៅហ្នឹងភូមិហ្នឹងមួយដែរទៅនៅណាស់។

ក៖ ហ៊ុ...ប្រវត្តិអ៊ុំដូចជាកម្សត់តែម្តង បែកអស់រលីង។

ខ៖ ហើយដល់ខ្ញុំមកនៅនេះបងណោះមកនៅភ្នំពេញវិញហើយណាស់ ដែលថាបាត់ខ្លួនហ្នឹងណាស់។

ក៖ ចាស!

ខ៖ នៅភ្នំពេញអញ្ចឹងហើយបងប្រុសឯណោះនៅជាមួយពូត្រពាំងលើក ខ្ញុំនៅខាងណោះនៅទន្លេបាទីឯនេះ ហើយបានលេងសើចជាមួយគ្នាគឺអត់ទេ។

ក៖ អត់ដែលបាននិយាយទៅដូចជាអ្នកក្រៅហើយ។

ខ៖ ចាស!

ក៖ អត់ដែលបាន។

ខ៖ អត់បានទេ អត់បានជួបទេ ហើយឃើញថាបានជួបគ្នាបានម្តង ពេលខ្ញុំមកនៅជាមួយពូម៉ែបាន១ឆ្នាំ មកអញ្ចឹងដូចមុខក្តាម ហើយទៅឯលិចវិញទៅ។

ក៖ បងប្អូនបង្កើតសោះគួរតែថាបានលេងជាមួយគ្នា ជិតស្និតជាមួយគ្នាអី។

ខ៖ អត់ទេអត់បានទេ។

ក៖ អត់ដូចបាត់ទាំងអស់គ្នា។

ខ៖ អត់ អត់ទេ ព្រោះបែក បែកកំព្រា ហ៊ី...ខ្ញុំគ្រាន់តែថាម៉ែស្លាប់ពូម៉ែទៅយកខ្ញុំពីត្រពាំងលើកមកទេតើ ពូម៉ែហ្នឹងហា...បានមកនៅនេះហ្នឹងហា៎...ពូម៉ែថាទេអញខ្មោចបងផ្ដាំមកណាស់ថាអត់ឱ្យង៉ែងនៅខាងម្ដាយទេអោយនៅខាងនេះ
ព្រោះអីខ្មោចឪគាត់ស្រលាញ់កូនស្រីអញ្ចឹងគាត់អត់ឱ្យនៅទេគាត់អោយមកនៅខាងនេះ
ពូម៉ែគាត់ទៅយកទេតើពេលនៅត្រពាំងលើកពូម៉ែទៅយកគាត់អត់ឱ្យនៅហ្នឹងណាស់
បានបានមកនៅជាមួយមីងជាមួយគាត់ហ្នឹង ពូម៉ែខ្ញុំនៅបាន២ឆ្នាំ
ពេលគាត់ទៅយកខ្ញុំអាយុ១០ឆ្នាំ
ពូម៉ែទៅយក។ពូម៉ែឱ្យពូម៉ុនឱ្យខ្មោចឪពុកចុងខ្ញុំហ្នឹងទៅយកពីបាត់ដំបងស្ទឹងហ្នឹងណាស់
ហ៊ី...ដល់មកដល់នេះពូខែចង់ឱ្យនៅជាមួយគាត់ ពូខែទៅយកមកនៅនេះ។

គ៖ ពូខែប្អូនធំម័រ?

ខ៖ ចាសប្អូនគាត់បង្កើតហើយពូខនហ្នឹង ហើយឥឡូវស្លាប់អស់ហើយ។

ក៖ ចុះអ៊ុំពេលតាំងពីតូចមកមានដែលធ្លាប់បានចូលរៀនសាលាអីខ្លះអត់អ៊ុំ?

ខ៖ អត់ទេអូន។

ក៖ អត់មានដែលបានចូលរៀនសោះ?

ខ៖ អត់ដែលបានរៀន។

ក៖ ថ្នាក់ទីប៉ុន្មានក៏អត់ដែលដែរ?

ខ៖ អត់ទេ អត់បានរៀនទេ។

ក៖ ឥឡូវអត់ចេះបានអានអក្សរខ្មែរឬក៏មើលអី?

ខ៖ អត់ទេៗ គ្រាន់តែមើលតែអក្សរឈ្មោះឯងមួយហ្នឹងមិនចង់រួចផង។

ក៖ ចេះសរសេរក៏អត់ចេះសរសេរដែរអ៊ុំហោ?

ខ៖ សរសេរយើងវាចេះតែយើងសរសេរបាន២ ៣តួហ្នឹង។

កៈ ចាស!

ខៈ ហើយអាហ្នឹងថាអត់ចេះតែម្ដងទៅ យើងវាអត់ចេះ។

កៈ ចុះអ៊ុំរាល់ថ្ងៃប្រកបការងារអីគេដែរអ៊ុំ?

ខៈ មានអីអូនធ្វើតែស្រែធ្វើតែចំការហ្នឹង។

កៈ ចាសអើរ....ចុះអ៊ុំរៀបការជាមួយអ៊ុំប្រុសដូចថាឪពុកម្ដាយផ្សំផ្គុំឱ្យយឬក៏...??

ខៈ អត់ទេអាពត។

កៈ ហ្ហ៎...អាពតជាអ្នករៀបឱ្យ?

ខៈ អាពតទេ ស្រុករហ្នឹងហ្ហ៎...។

កៈ ចុះអ៊ុំក៏អត់ជំទាស់ដែរ?

ខៈ អ្នកណា?

កៈ អ៊ុំអត់ជំទាស់នឹងប៉ុល ពតដែរ?

ខៈ អត់ទេ។

កៈ ជំទាស់អត់កើត?

ខៈ ចាស!

កៈ
ចាសអ៊ុំជីវិតអាពាហ៍ពិពាហ៍អ៊ុំដូចថារស់នៅជាមួយគ្នាសុខសប្បាយអត់ឬក៏មានបញ្ហាខ្លះៗអីអត់?

ខៈ មានខ្លះដែរ មានតិចតួចណាស់។

កៈ ចាសចុះអ៊ុំមានកូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ៩។

ក៖ ៩នាក់ ? គាត់ឈ្មោះអីគេខ្លះដែរអ៊ុំ?

ខ៖ ឈ្មោះទីមួយ ឈ្មោះភក្ត្រ័។

ក៖ ឈ្មោះភក្ត្រ័?

ខ៖ ទី២ឈ្មោះហៃម ទី៣មីស្រស់ ទី៤ ចង់ភ្លេចឈ្មោះកូន ទី៤អាម៉ៅ អាម៉ៅឈ្មោះម៉ៅហាំ...។

ក៖ ចាស!

ខ៖ ទី៥ជុំ ស្រីតូច ទី៦ ចង់ភ្លេចហើយនេះ មើលមិញប៉ុន្មានហើយ?៦ហើយ?

ក៖ ចាស!

ខ៖ ទី៧ ជុំ ទី។

ក៖ ចាស!

ខ៖ ទី៨ ជុំ អ៊ែង ជុំ សុខនី ទី៩ជុំ ស្រីពៅ។

ក៖ ចាសអ៊ុំកូនច្រើនដែរ។

ខ៖ កូនច្រើនមាន៩។

ក៖ ចាសមានគ្រួសារហើយៗអ៊ុំហី?

ខ៖ មាន៤ហើយនៅ៥ទៀត។

ក៖ ចាសពួកគាត់សុទ្ធតែនៅម្តុំហ្នឹងទាំងអស់ឬក៏មានបែកទៅខេត្តណាផ្សេង?

ខ៖ នៅអូន នៅខាងខេត្តកណ្តាលស្ទឹង។នៅខាងស្រុកល្វាឯម ខេត្តកណ្តាល។

គ៖ មីមួយណា?

ខ៖ មីមួយល្អិតជាងគេថាបេះដូងហ្នឹង ធ្លាប់ទៅផ្ទះហ្អែងដែរតើ។

ក៖ អត់សូវចាំ ថាអ្នកណាគេខ្លះ។

ខ៖ ភ្លេចមិញហ្នឹងទី៤ជុំ ស្រីមិញ ទី៥ អើរ ជុំ ម៉ៅ ទី៦ ស្រីទូច ទី៧ជុំ ទី ទី៨ ជុំ ស្រីនី ទី៩ស្រីពៅមិញហ្នឹងមកចិតស្វាយអម្បាញ់មិញហ្នឹង។

ក៖ យូរៗដូចថាចង់វគ្គហាំ...។

ខ៖ ចង់វគ្គកូនច្រើន។

ក៖ កូនច្រើនពេក។ពេលខ្លះភាំងណាស់ដូចថាអត់នេ...ចុះពួកគាត់សុទ្ធតែបានរៀនតើអ៊ុំហែ?

ខ៖ បានរៀនតើអូន គ្រាន់តែថាបានរៀនថ្នាក់តិចណាស់។

ក៖ ចាស!

ខ៖ បានច្រើនជាងគេបានតែ៣នាក់ទេ ប៉ុន្តែវាប្រលងធ្លាក់ទាំង៣ណាស់។

គ៖ ពួកវាអត់សូវបានរៀនតែសុទ្ធតែចេះអង់គ្លេស។

ខ៖ ហ្នឹងហើយ អក្សរខ្មែរវាអន់ណាស់ វាគ្រាន់អង់គ្លេស។

ក៖ ចាស!

ខ៖ ហើយឯងណោះហ្អែងដឹងអាមួយជុំ ម៉ៅហ្នឹងទេវាថាអត់ឱ្យប្រាប់គេទេ វាថាវាចេះ វាកត់ចំនួនឱ្យគណបក្សសង្គ្រោះជាតិហ្នឹង។

ក៖ ហ៊ឺ...!

ខ៖ គេដឹងអាហ្នឹងគេអត់ឱ្យយើងជាប់ទាំងអស់ អត់ជាប់ទាំងអស់។

ក៖ និយាយទៅឱ្យតែពាក់ពន្ធ័នឹងគណបក្សសង្គ្រោះជាតិគឺវាបំផ្លាញចោលទាំងអស់ហ្មងហា។

ខ៖ អត់ឱ្យជាប់ទាំង៣ អត់ជាប់រលីង ហើយវារៀនពូកែដែរតើ។

ក៖ ចាស!

ខ៖ អញ្ចឹងអត់ទេ។

ក៖ ស្តាយណាស់អ៊ុំ។

ខ៖ គេដឹងគម្រោងវាណាស់។

ក៖ គ្រាន់តែយើងទៅជួយ។

ខ៖ ទៅទៅជួយអង្កេតការហ្នឹង។

ក៖ ចាស!

ខ៖ មានឱ្យជាប់ឯណា ប្រលងទាំង៣នាក់ធ្លាក់ទាំង៣នាក់ថ្នាក់ទី១២ សូកលុយហើយវាអត់ឱ្យជាប់ទៀតខ្ញុំប្រាប់ហ្មែង គ្រាន់តែថាអង់គ្លេសវាពូកែ។

ក៖ ចុះគាត់បានធ្វើការអីគេខ្លះអត់អ៊ុំ?

ខ៖ ប្អូនអត់ទេ វាគ្រាន់តែវារកស៊ីធម្មតាណាស់ ចាសអត់បានប្រលងធ្លាក់ទាំង៣ហ្មែងគិតមើល។

ក៖ តែគាត់ពូកែអង់គ្លេសដែរគួរតែរកការងារអីផ្សេងៗធ្វើ។

ខ៖ អត់ទេ មួយវារកស៊ីអ៊ុតសក់ណាស់ ហើយមីពៅនៅរៀនថ្នាក់ទី១២។

ក៖ ចាស!

ខ៖ នៅរៀនតែមួយហ្នឹងទេ?

ក៖ នៅរៀនតែមួយទេ ចុះមួយធំថាទៅភ្នំពេញនោះ គាត់មិញ?

ខ៖ បានថ្នាក់ទី៩។

ក៖ ទី៩។ ចាសអ៊ុំកាលពេលនៅក្មេងចូលចិត្តធ្វើអីគេជាងគេទៅ?

ខ៖ មានធ្វើអីហាអើយ ធ្វើតែស្រែតែចំការ ធ្វើនំលក់ធ្វើអីហ្នឹងណាស់។

ក៖ ចាសអ៊ុំប្រកបការងារអីគេខ្លះទៅតាំងពីក្មេងមក?

ខ៖ មានធ្វើអីមានតែធ្វើនំលក់ហ្នឹងអូនណាស់។

កៈ ចាសអ៊ុំចេះធ្វើនំអីគេទៅ?

ខៈ គ្រប់បែបគ្រប់យ៉ាង នំអន្សមក៏ចេះទ្រាបបាយ អីមួយចប់ណាស់អូន អាកោរ ចាក់ចុល នំគម នំបត់ អន្សម។

កៈ លក់នៅក្នុងភូមិហ្នឹង?

ខៈ ចាស!

កៈ អ៊ុំចេះមកពីចាស់ៗបង្រៀនឬគ៏គ្រាន់តែមើលគេចេះធ្វើ?

ខៈ ចេះមីងបង្រៀន។

កៈ ចាស!

ខៈ នៅជាមួយមីងឡូហ្វ៊...។

កៈ ចាស!

ខៈ ដល់ពេលនេះគាត់ចេះតែបង្ហាញធ្វើនេះធ្វើនោះអញ្ចឹងទៅណាស់។

កៈ ចាសអ៊ុំដុងខាងហ្នឹង អ៊ុំដូចថាក្នុងខ្លួនហ្នឹងដូចថាមានជំនាញអីគេផ្សេងទៀតក្រៅពីធ្វើនំហ្នឹងធ្វើស្រែអីអត់អ៊ុំ?

ខៈ អត់ អត់មានទេ មានដុងតែប៉ុណ្ណឹង។

កៈ ចុះគ្រួសាររបស់អ៊ុំលោកពូគាត់រស់នៅណាតាំងពីក្មេងមក?

ខៈ នៅហ្នឹងដែរអូន កំណើតនៅហ្នឹង មានគ្រួសារក៏នៅហ្នឹង។

កៈ អ៊ុំសមានចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់អត់អ៊ុំ?

ខៈ អត់ ស្គាល់តែឆ្នាំដែរ។

កៈ ឆ្នាំអីគេទៅអ៊ុំ?

ខៈ ឆ្នាំច ។

កៈ ចាសហើយទីកន្លែងកំណើតរបស់គាត់នៅកន្លែងហ្នឹងដែរ?

ខៈ ចាសនៅហ្នឹងដែរ។

កៈ ពេលនៅក្នុងអាពតបានជួបគ្នាទៀត?

ខៈ ចាស!

កៈ អ៊ុំមានធ្លាប់ទៅលេងខេត្តណាខ្លះដែរអត់អ៊ុំ?

ខៈ ដែលតើអូន។

កៈ ទៅលេងខេត្តណាទៅអ៊ុំ?

ខៈ កោះកុង កំពង់សោមអី។

កៈ បានឆ្ងាយតើអ៊ុំ ហើយចុះមានទៅប៉ែកខាងផ្សេងៗទៀតអត់អ៊ុំ?

ខៈ ទៅរតនៈគិរី មណ្ឌលគិរី។

កៈ ហ្វ៎...ធ្លាប់ទៅដល់មណ្ឌលគិរី រតនៈគិរីដែរ។

ខៈ ខាងព្រះវិហារ។

កៈ ឆ្ងាយៗណាស់!!

ខៈ ឡាវ។

កៈ ខ្ញុំអត់ដែលបានទៅសោះខាងប៉ែកឥសានហ្នឹង។

ខៈ មណ្ឌលគិរី រតនៈគិរីខ្ញុំទៅអស់ហើយៗ កោះកុងតែគ្រាន់តែយើងដើរត្រួសៗទេណាស់។

កៈ ចាសអ៊ុំកូនចៅយកទៅ ឬក៏អត់មានទៅលេងជាមួយជុំជាមួយកូនចៅណាអ៊ុំហោ?

ខៈ អត់ទេ ខ្ញុំទៅតែឯង។

កៈ ហ៊ី...ទៅជាមួយទៅជាមួយអ្នកភូមិដែរ?

ខ៖ ទៅជាមួយអ្នកភូមិ។

ក៖ ហ្អ៎...គេទៅជុំៗគ្នាគេជួលឡានទៅ?

ខ៖ ចាសហ្នឹងហើយ។

ក៖ អ៊ុំទៅបានប៉ុន្មានថ្ងៃទៅយូរដែរទេតើអ៊ុំហោ?

ខ៖ ទៅបាន៣ ៤យប់។

ក៖ តែសប្បាយខ្លាំងណាស់នៅទីនោះ?

ខ៖ ចាស!

ក៖ ទេសភាពស្អាតវាខុសពីនេះណាស់។

ខ៖ ចាសស្អាតហើយអញ្ចឹងតទៅទៅសុរិន្ទ ទៅមើលខ្លួនទេណាស់ ទៅសុរិន្ទ។

ក៖ ហ្អ៎...!

ខ៖ ទៅសុរិន្ទទឹកដីថៃអត់ដែលទៅ?

ក៖ នៅ។

ខ៖ ខេត្តសុរិន្ទ។

ក៖ អ៊ុំឈឺអីគេអ៊ុំ?

ខ៖ យើងយកកូនទៅ វះបេះដូង។

ក៖ ហ្អ៎...!

ខ៖ មិញកូនខ្ញុំកុំតែបានថ្នាំហ្នឹងទេណាស់ បើសិនជាថ្នាំនៅទីនេះងាប់បាត់ ដាក់អត់ត្រូវណាស់ ដាក់ទៅនៅតែចេះដង្ហក់ វាបាត់តែកន្លែងពេទ្យកាល់ម៉ែត្រហ្នឹង ដល់តែពេលដូរថ្នាំថ្មីមិនដឹងថ្នាំអីថ្នាំអី។

គ៖ ដល់ពេលទៅអញ្ចឹងធូរ។

ខ៖ ធូរ។

ក៖ ចាសសុទ្ធតែជម្ងឺសុទ្ធតែយ៉ាប់ៗ អញ្ចឹងត្រូវតែទៅរហូតអញ្ចឹងអ៊ុំហោ?

ខ៖ ទៅរហូត ទៅរហូតអញ្ចឹងយើងមាន៣០០យើងអត់អស់ទេនាង អស់តែថ្លៃថ្នាំទេណាស់។

ក៖ អ៊ុំធ្លាប់ដឹងថាពេលឪពុកម្ដាយអ៊ុំនៅរស់គាត់ដឹងធ្វើការងារអីទេអ៊ុំ?

ខ៖ អត់ទេអូនគាត់ធ្វើតែការងារស្រែចំការដែរហ្នឹង។

ក៖ ចាសពួកគាត់មានដែល កាលគាត់ស្លាប់ហ្នឹងអ៊ុំអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំហោ?

ក៖ ចាសខ្ញុំភ្លេចបាត់ហើយ។

ខ៖ ៨ឆ្នាំ។

ក៖ ៨ឆ្នាំ។

ខ៖ ឪពុកស្លាប់អាយុ១ឆ្នាំ។

ក៖ អឺ...ពួកគាត់មានដែលធ្លាប់និយាយរឿងរ៉ាវអីរបស់ពួកគាត់នៅក្មេងៗអីប្រាប់អ៊ុំអត់អ៊ុំ?

ខ៖ អត់ ពីព្រោះគាត់អាយុខ្លីពេកណាស់អូនយើងអត់ដឹង។

ក៖ ចាស!

ខ៖ អាយុខ្លីណាស់ ឪពុកអាយុខ្លីណាស់។

ក៖ អ៊ុំនៅចាំមុខគាត់តើអ៊ុំហោ?

ខ៖ អត់ស្គាល់មុខឪពុករបៀបម៉េចទេ គ្រាន់ម៉ែនៅស្រពិចស្រពិល ភ្លេចហើយអូនអើយវាយូរហើយអូន។

ក៖ អ៊ុំធ្លាប់ឆ្លងកាត់ជំនាន់អាពតម៉េចខ្លះទៅអ៊ុំ គេដូចថាគេឱ្យអ៊ុំធ្វើការងារអីគេខ្លះទៅ?

ខ៖ រែកដីអូន រែកដីធ្វើដី។

ក៖ អ៊ុំនៅអាយុប៉ុន្មានពេលនៅជំនាន់អាពតហ្នឹង?

ខ៖ អាយុ១៧ ១៨ ២២ហើយណាស់នៅក្បែរខ្ទង់១៧ ១៨។

ក៖ ចាស!

ខ៖ ចូលយើង២២រៀបប្តីប្រពន្ធឱ្យហ្នឹង។

ក៖ ចាស!

ខ៖ យើងរៀបយើងឆ្នាំយើងចុងឆ្នាំ៧៨(១៩៧៨)ខ្ញុំរៀបហ្នឹងណាស់។

ក៖ ចាសអ៊ុំនៅជំនាន់អាពតដែលហូបឆ្អែតអត់អ៊ុំ?

ខ៖ ហ៊ឺ...ឆ្អែតពីណាមកអូន។

ក៖ ហូបបានតែបន្តិច?

ខ៖ ឆ្អែតដូចថា១០ថ្ងៃវាមាន២ថ្ងៃដែលឆ្អែត។

ក៖ ចាស!

ខ៖ ព្រោះអីរបស់វាលួចគេ ព្រោះអីលួច។

ក៖ អ៊ុំអត់មានចិត្តថាចង់លួចរត់ចេញពីកន្លែងអាពតហ្នឹងអីទេហី?

ខ៖ លួចរត់ទៅកន្លែងណាអូន បើយើងអត់ទាន់បានស្គាល់ទៅកន្លែងណាបានគ្រប់សព្វផង។

ក៖ ចាសតែបើលួចរត់ក៏រត់អត់កើតដែរខ្លាចវាសម្លាប់ចោល ចុះអ៊ុំប្រុសគ្រួសាររបស់អ៊ុំហ្នឹងគាត់ធ្លាប់ធ្វើការងារអីគេខ្លះទៅអ៊ុំ?

ខ៖ ធ្វើស្រែចម្ការទាំងអស់។

ក៖ ស្រែចម្ការដែរ?

ខ៖ ចាស!

ក៖ ចុះគាត់ធ្លាប់អត់មានធ្លាប់ប្រកបការងារអីផ្សេងៗទេហោ?ហើយចុះមានធ្លាប់បានទៅស្គាល់ខេត្តណាអីខ្លះអត់អ៊ុំ?

ខ៖ ស្គាល់តែស្វាយរៀង ក្រុងព្រះសីហនុ ហើយនឹងព្រះវិហារ។

ក៖ ស្គាល់បានឆ្ងាយៗដែរ គាត់នៅមានកម្លាំងដើរដើរចេះតែដើរខ្លះទៅកុំឱ្យនៅតែផ្ទះពេកតែចាស់ទៅយើងពិបាកដើរលេងណាស់។

ខ៖ អត់បានដើរលេងយើងអត់ដែលស្គាល់ព្រោះយើងនៅស្រុកខ្មែរយើងស្គាល់ស្រុកខ្មែរអត់អស់ទៀត។

ក៖ ចាសបើមានឪកាសបានទៅស្គាល់ស្រុកក្រៅទៀតរឹតតែល្អ។

ខ៖ អត់ទេខ្ញុំ អត់ទាន់បានធ្វើប៉ាស់ស្ព័ កូនគឿនឱ្យទៅដែរតានោះគាត់ប៉ារកាប៉ាល់ហោះតែខ្ញុំអត់ទាន់ធ្វើប៉ាស់ស្ព័រ។

ក៖ ធ្វើទៅអ៊ុំ។

ខ៖ ជាប់ធ្វើ។

ក៖ ធ្វើអស់តែ១០០ជាងហ្នឹង។

ខ៖ ចាសវាឱ្យទៅធ្វើតើ។

ក៖ ទៅធ្វើទៅអ៊ុំ។

ខ៖ នោះគាត់ចង់ឱ្យទៅលេង យើងចង់ទៅឯណាគាត់ឱ្យទៅ សាំង ហ្គាពួរឬក៏ថៃគាត់ឱ្យទៅទេតើគាត់បបួលទៅយូរហើយ គាត់ថាចង់ទៅទេគាត់ថាអញ្ចឹង។

ក៖ គាត់ជនជាតិអីគេអ៊ុំ?

ខ៖ អូស្ត្រាលី។

កៈ អូស្រ្តាលី?ហើយគាត់ប្រុងរៀបការកាលអុំ?

ខៈ អត់ទេវាអត់ព្រមទេ។

គៈ គាត់ចូលចិត្តយើង។

ខៈ គាត់ចូលចិត្ត គ្រួសារយើង។

កៈ ចាស!

ខៈ គាត់មកដូចថាគាត់នាំដើរលេងអញ្ចឹងទៅណាស់។

កៈ ហ្ហ៎...មិនមែនដូចថាគាត់ចង់ចូលស្ដីកូនទេហេ?

ខៈ អត់ទេ គាត់រាប់អានកូនខ្ញុំអាកូនប្រុស។

កៈ ហ្ហ៎...!

ខៈ មានន័យថាគាត់ចាស់គាត់អាយុ៦០ហើយគាត់គ្រាន់តែដើរទៅណាគ្រាន់តែបានជាគ្នា

អញ្ចឹងទៅណាស់។

កៈ គាត់អាយុច្រើនដែរហើយ។

ខៈ គាត់អាយុច្រើនប៉ុន្តែគេមានហាំ។

កៈ ចាស!

ខៈ ស្រុកគេគេមានគេរកអ្នកគ្រាន់តែដើរជាមួយអញ្ចឹងទៅណាស់ គ្រាន់តែយើងទុកចិត្ត។

កៈ គាត់ធ្លាប់មកលេងហ្នឹងដែរតើអុំហេ?

ខៈ ធ្លាប់មកលេងតែញឹក ឱ្យតែមក មកដល់ហើយ ឱ្យតែមកមកដល់នេះដាក់អីហូប ហូបទាំងអស់។

កៈ គាត់ចេះហូបរបស់ខ្មែរដែរហេ?

ខ៖ ចាស!

ក៖ អ្នកខ្លះដាក់អត់បានទេណាស់ ដាក់ទៅធ្វើទុក្ខតែម្តង។អ៊ុំមានចាំកាលពេលប្រវត្តិកាលពេលនៅក្មេងអីម៉េចៗខ្លះអត់អ៊ុំ?

ខ៖ អត់មានចាំអីទេ ចាំតែយើងនៅពីក្មេងយើងនៅជំនាន់អាពតយើងរែកតែដីហ្នឹង។

ក៖ ចាស!

ខ៖ រែកដីធ្វើជីធ្វើអីហ្នឹង។

ក៖ អ៊ុំកាលពេលទៅនៅបាត់ដំបងអត់មានបានរៀនបានអីដែរហេ?

ខ៖ រៀនណាអូន ខ្ញុំនៅមើលប្អូន។

ក៖ ហ្អ៎...!

ខ៖ អាប្អូនម៉ែជាមួយគ្នាឪពុកដោយខ្លួនហ្នឹង។

ក៖ ចាស!

ខ៖ ដែលថាវាបាត់ខ្លួនហ្នឹងណាស់។

ក៖ ចាស!

ខ៖ មើលប្អូន២នាក់ហ្នឹង។

ក៖ អ៊ុំចូលចិត្តម្ហូបអីគេជាងគេអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតែម្ជូរ ម្ជូរគឺចូលចិត្តលើសគេ ឆាល្មមទេ។

ក៖ ចាស!

ខ៖ ហើយនឹងកកូរ តែ២មុខហ្នឹងទេ។

ក៖ ចាសវាអត់ត្រលាន់។

ខ៖ ចាស!

ក៖ អ៊ុំ ចេះធ្វើម្ហូបគ្រប់មុខតើអ៊ុំហី?

ខ៖ ចេះតែម្ហូបស្រែយើងទេ។

ក៖ ចាសសម្លរការីសម្លរអីចេះធ្វើដែរ?

ខ៖ ចេះ។

ក៖ សម្លរការីដូចជារៀងពិបាកជាងគេ។

ខ៖ ចាសពិបាកប៉ុន្តែយើងធ្វើកើត យើងចេះតែយើងក៏មិនមែនប្រសប់ខាងហ្នឹងដែរ។

ក៖ ហើយអ៊ុំពេលដែលអ៊ុំនៅតូចៗហ្នឹង ម្តាយឪពុកអ៊ុំហ្នឹងក៏មិនដែលធ្លាប់និយាយពីជីដូនជីតាគាត់អីដូចថាឪពុកម្តាយរបស់គាត់តទៅទៀតអញ្ចឹងទៅណាស់?

ខ៖ អត់ អត់ទេអូន អត់ដែលនិយាយពីប្រវត្តិអីនិយាយប្រាប់យើងទេណាស់។

ក៖ ចាសរស់នៅបានជាមួយគាត់តិចពេក។

ខ៖ តិចពេកឪពុកអត់ស្គាល់ទេ អាយុបានមួយឆ្នាំអត់ស្គាល់មុខឪពុកទៅ។

ក៖ ចាសអត់ស្គាល់។

ខ៖ បើ៩ឆ្នាំយើងអាចស្គាល់ខ្លះណាស់ យើងនៅក្មេងយើង៩ឆ្នាំអាចបានស្គាល់ស្រពិចស្រពិលបានខ្លះ។

ក៖ ហើយអញ្ចឹងអ្នកដែលអ៊ុំនៅជាមួយគេអ្នកដូចថាយកអ៊ុំមកនៅជាមួយគេអត់ដែលធ្លាប់និយាយពីប្រវត្តិឪពុកម្តាយរបស់អ៊ុំទេហោ?

ខ៖ អត់ទេគាត់អត់និយាយ។

ក៖ ពួកគាត់ដូចជាឪពុកម្តាយរបស់អ៊ុំទី២ហើយ?

ខ៖ ចាស!

ក៖ ហើយពូកគាត់សព្វថ្ងៃពូកគាត់នៅរស់តើអ៊ុំហី?អ្នកដែលចិញ្ចឹមអ៊ុំតាំងពីនៅតូច?

ខ៖ ស្លាប់អស់ហើយ ពូម៉ែក៏ស្លាប់ យាយទ្បក៏ស្លាប់ នៅតែតាបាន គាត់ស្លាប់អស់ហើយបងខ្ញុំបង្កើតក៏ស្លាប់ដែរ។

ក៖ ចាស!

ខ៖ ស្លាប់អស់ហើយ។

ក៖ ចុះកាលអ៊ុំនៅជាមួយពូកគាត់ ការងារអីដែលអ៊ុំជួយពូកគាត់បានខ្លះទៅអ៊ុំ?

ខ៖ ជួយយើងរកអុស យើងជួយមើលប្អូនអីហ្នឹងណាស់។

ក៖ ចាស!

ខ៖ មានតែប៉ុណ្ណឹងអូនជួយ។

ក៖ ចាសហេតុអីបានជាគាត់យកអ៊ុំទៅចិញ្ចឹមវិញ?

ខ៖ គាត់អាណិតហ្នឹង។

ក៖ គាត់អាណិត។

ខ៖ គាត់អញ្ចេកដូចថាខឹងយើងខឹងមីងមាយើងនៅពីតូចហាំ ដូចថាខឹងគាត់ថាឱ្យតិចតួចអាងតែផ្ទះមីងមាច្រើនយើងទៅនៅហ្នឹងអញ្ចឹងទៅណាស់។

ក៖ ចាសដូចវាប្រវត្តិច្រើនណាស់អ៊ុំប្រវត្តិជូរចត់។ចុះអ៊ុំកាលពេលការហ្នឹងអាពតរៀបឱ្យមិនមែនដូចថាអី ចាស់ៗអីផ្សំផ្គុំអីទេ?

ខ៖ ចាស!

ក៖ ចុះអ៊ុំពេលដែលជួបអ៊ុំប្រុសហ្នឹង ដូចថាតាំងពីមុនធ្លាប់ជួបគ្នាហ្នឹងមានរឿងរ៉ាវអីខ្លះនៅអ៊ុំ?

ខ៖ អត់ៗមានរឿងរ៉ាវអីទេ គូរព្រេងតែម្តង។

ក៖ ចាសពីមុន ពីមុនដែលស្គាល់គ្នាដែរ?

ខ៖ ស្គាល់គ្រាន់តែមួយស្គាល់ប៉ុន្តែខ្ញុំអត់ដែលទាក់ទងទេ។

ក៖ ចាសអត់ដែលមិនមែនជាមិត្តភក្តិមិនមែនជាអីទេអ៊ុំណោះ?គ្រាន់តែធ្លាប់នៅជិតគ្នា?

ខ៖ ចាស!

ក៖ គ្រាន់តែអ្នករួមភូមិនៅជាមួយគ្នាអី?

ខ៖ ចាស!

ក៖ ចុះអ៊ុំមានដឹងរឿងអីគេខ្លះទាក់ទងនឹងគ្រួសារអ៊ុំអត់?

ខ៖ អត់ទេ។

ក៖ ពីមុន អត់ដែល?

ខ៖ អត់ដែល ។

ក៖
អត់ដែលដឹងពីប្រវត្តិគ្រួសារថាគាត់យ៉ាងម៉េចៗអីទេហោ?រយៈពេលមកដល់ឥឡូវអ៊ុំការបានប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖
មកតាំងពីឆ្នាំ៧៨(១៩៧៨)ពីចុងឆ្នាំ៧៨(១៩៧៨)មកឥឡូវអូនឯងរាប់មើល៧៨(១៩៧៨)៧៩(១៩៧៩)។

ក៖ ចង់៤០ហើយហោ...។

ខ៖ ចង់៤០ ៤០ហើយណាស់

ក៖ ៤០ហើយ។

ខ៖ គិតមើល។

ក៖ ច្រើនដែរ។

ខ៖ ឆ្នាំ៧៩(១៩៧៩)ដល់យើងបានមួយឆ្នាំអើរ...ចុងឆ្នាំ៧៨(១៩៧៨)79(1979)ចុងឆ្នាំទៀត។ហើយខ្ញុំរៀបខែកក្ដិក ខែកក្ដិកអាហ្នឹងខែប៉ុន្មាន ខែ១០ខែ១១ហើយណោះ?

គ៖ ចាំទៀតណាស់។

ខ៖ ចុះបើឯងកំពុងតែភ្លៀងរអិលសស្រាក់ៗ ហើយខ្មោចតាខាន់ថាហុី...គេស្ដីកូនអញកាលហ្នឹងគាត់ស្រលាញ់ខ្ញុំដែរនោះ កូនអញស្ដីអានោះគេមិនយកស្ដីអានោះគេមិនយកគិតទៅបានកូនចិន កាលហ្នឹងមីសៀងហ្នឹងធ្វើការជាមួយខ្ញុំហើយនៅផ្ទះជិតគ្នាគាត់ចេះតែចេញចូលចេញចូលគាត់ចេះតែនិយាយគ្នាលេងអញ្ចឹងទៅណាស់ កូនអញអាណាឆ្មាក្រញ៉ាឆ្មាក្រញៅមុខវាវាខាំឆ្មាក្រញៅ ដល់ហើយបានមីសៀងហ្នឹងវាមនុស្សល្អកូនចិននោះ គេសរមុខគេស្អាត ហើយគាត់ថាគេប្រកែកគ្រប់គ្នាបានកូនចិនដែរហ្នឹងប្រពន្ធកូនប្រសារគាត់ហ្នឹងគាត់ពូកែខាងនិយាយលេង និយាយលេងក្មេងៗ។

ក៖ចាស!

ខ៖ ឥឡូវគេសំណាងទៅគេនៅភ្នំពេញហ្នំ...គេមានណាស់ឥឡូវ។

ក៖ ចុះអ៊ុំដូចថាអ៊ុំមានចេះភាសាអីផ្សេងអីគេផ្សេងក្រៅពីភាសាខ្មែរទេអ៊ុំ?

ខ៖ ខ្ញុំអត់ទេចេះតែភាសាខ្មែរហ្នឹង។

ក៖ ចាសព្រោះចាស់ៗជំនាន់មុនព្រោះគេថាធ្លាប់ចេះបារាំងអីអញ្ចឹងណាស់តែឥឡូវអត់មាន។ចុះអ៊ុំធ្លាប់មានមិត្តភក្ដិជិតស្និតធ្លាប់លេងជាមួយគ្នាអីទេ?

ខ៖ អត់មានទេ មានតែកាចុចហ្នឹង ពីរនាក់ហ្នឹង។

គ៖ វារ៉ៃគ្នានោះ។

ក៖ មានតែលេងជាមួយគ្នា។

ខ៖ រឿងដណ្ដើមបង្អែមគ្នា ខ្ញុំលាក់ខ្ញុំច្រើនតែលាក់ ថុចវាខ្ចិលណាស់ ឱ្យជួយធ្វើវាអត់ជួយធ្វើទេ ដល់ពេលឯងធ្វើឆ្អិនវាទៅរក ហើយខ្ញុំថាស៊ីអស់ហើយតែលាក់ទេណាស់ ដណ្ដើមគ្នាទាល់តែក្រពប់ទៅ។

គ៖ ហើយទទួលពូបានកំពុងតែសម្រាន្ត រ៉ែនឯងនិយាយហ្នឹងឱ្យអស់មើល។

ខ៖ ត្រង់កន្លែងហ្នឹង កាលពេលហ្នឹងបោក បោកពូបានគាត់អស់កម្លាំងគាត់នោះ យប់ម៉ោង១១ ១២ហើយហ្នឹង ហើយទៅមើលរឿងឆាកកំប្លែងហើយនាំគ្នានិយាយពីរឿងឆាកកំប្លែង លែងពូបានថាកុំនិយាយវើយ អញថ្លង់ណាស់អញដេក ដល់ហើយគាត់ថាតែអញ ដល់ពេលគាត់ដាក់ ក្រោមកាថុចដេកយកជើងវាដាក់ពីលើទៅត្រូវតែជើងវា។

ក៖ ហើយអ៊ុំសម្រាន្តជាមួយគ្នា?

ខ៖ ហ្នឹងហើយ នៅតូចៗនោះ។

ក៖ ហើយក្រលំភួយជិតអស់ទៅ។

ខ៖ ក្រលំឱ្យជិតទៅយើងយកជើងវាដាក់ពីលើជើងឯងទៅណាស់ ដេកអង្គុញនោះដល់ពេល

អញ្ចឹងជើងវាមិនលប់លើជើងឯងអញ្ចេះ។

ក៖ ចាស!

ខ៖ យើងអង្គុញវាសន្លូកមិនប៉ះតែវាប៉ះវា។

គ៖ ដល់រ៉ែត្រូវតែថុចហើយរ៉ែនគិតតែពីសើច។

ក៖ នៅក្មេងៗដូចជាប្រវត្តិអា...?

ខ៖ នៅពីក្មេងប្រវត្តិនិយាយទៅថុចចាញ់បោកខ្ញុំតែរហូត វាឆ្លាតក៏ឆ្លាតដែរចាំមើលខែដូរត្រីមង ដាក់អួនបាននាំគ្នាធ្វើហើយអាត្រីច្រវាយកុកខ្ទងវែងនោះ
យើងមិនយកអាចមន៍ចេញហើយយើងមិនលាងហើយស្អាតនៅកំពុងនេះមាត់ទន្លេហ្នឹងហើយ ហើយធ្វើហើយមកបេះដៃត្រកៀតស្លរម្ទូរ ស្លរម្ទូរស្លឹកអំពិលដើមឆ្នាំអញ្ចឹង

អាស្លឹកអំពិលទើបតែលាស់ហ្នឹងណាស់ លបៗហ្នឹងបេះមកស្ល ស្រាប់តែស្លរយើងចុះបេះៗស្រាប់តែអញថីឈឺរម៉ាស់ៗ។

គ៖ ឈ្លើងទាម?

ខ៖ ឈ្លើងទាម មើលទៅលឿងហើយនិងខៀវ ឡើងខ្មៅពាឈ្លើងសម្បុរ ស្តាប់តែមើលទៅប៉ុនសំបើងទុំអញ្ចេក វាកន្លែងដំបៅខ្ញុំអញ្ចឹងនោះស្រាប់តែខ្ញុំទាមទៅខ្ញុំហៅថុចង៉ែងមកជិតអញមកគ្រាន់តែលើកមើលម្តងទៀតបាត់ ដល់ពេលម្តងទៀតជាប់ដល់ពេលហើយប្រាប់ថុចង៉ែងមកជិតអញៗប្រាប់ង៉ែងរឿងមួយ ង៉ែងមកអោយជិតមក ប៉ុន្តែឈ្លើងទាមទេណាស់ អត់ហ៊ានថាឈ្លើងទាមទេខ្លាចកាថុចរត់។

ក៖ ហ្ហ៎....!

ខ៖ ដល់ពេលមកជិតថាថុចអើយឈ្លើងទាមអញ កៀកកវាយកជើងក្លួតជើងវាក្លួតទាល់តែដាច់មីនោះរត់ស្រាតខោស្រាតអាវទៅកំពុងយាយកានពីរនាក់វិញទៅណាស់ដល់ពេលអញ្ចឹងទៅលាងដៃគ្រកៀតនៅកំពុងយាយកាននោះ។

ក៖ នៅទន្លេហ្នឹងសំបូរឈ្លើងអ៊ំហេ?

ខ៖ ចាសកាលហ្នឹង ឈ្លើងឥឡូវក៏នៅតែមាន ដល់មកកំពង់យាយកាន ដល់ពេលមកដីខ្សាច់នេះលុតជង្គង់លាងវាឱ្យវាស្អាត អាជាតិកាលីដីរុំដៃគ្រកៀតហ្នឹងនាំគ្នាលាងឱ្យស្អាតអញ្ចឹងហើយងូតទឹកព្យស្អាតហើយលុតជង្គង់ លុតជង្គង់វាតោងខោតោងសំពត់វានោះ។

ក៖ អូយ...!

ខ៖ ថុចណាស់ឈ្លើងហ្នឹងវាមានធ្លាក់បាត់ឯណា វាតោង វាថាង៉ែងរ៉នមកមកនេះអញខ្សឹបរឿងមួយ យើងដឹងថាច្បាស់ជាឈ្លើងហ្នឹងអត់ទៅណាទេតោងលើសំពត់យើងវាហើយ គ្រាន់តែឃើញហើយរត់ផៃ ថាវាប្រចោរខ្ញុំ មាត់ចៃថុបតែម្នាក់ឯងហ្នឹង ថាអើយ...សារ៉នអើយអញចាញ់តែបញ្ញាង៉ែងរហូតយ៉ាងនេះ ល្អសើចដែរហ្នឹងពីរនាក់ហ្នឹងឈ្លោះគ្នាតែរហូត។

កៈ អ៊ុំដើរតែជាមួយគាត់រហូត?

ខៈ ហ្នឹងហើយឈ្លោះគ្នាតែត្រូវគ្នាឆាប់។

កៈ ហ្នឹងហើយ ឈ្លោះជាមួយគ្នាតែដើរតែជាមួយគ្នា?

ខៈ ហ្នឹងហើយ ឈ្លោះគ្នាញឹកតែត្រូវគ្នាក៏ច្រើនហើយលឿនដែរ។

កៈ គាត់ឥឡូវនៅជិតហ្នឹងដែរ?

ខៈ អត់ទេនៅសំរោងយោងហ្នុ៎...។

កៈ ចាស!

ខៈ តែយើងនិយាយកាលពេលនៅតូចណាស់។

កៈ ចាស!

ខៈ តាំពីពួកយើង៧ឆ្នាំ ៨ឆ្នាំ ១០ឆ្នាំជាងឯណោះ។

កៈ អ៊ុំឧស្សាហ៍ជួបគ្នាទេឥឡូវ?

ខៈ ឥឡូវអត់សូវជួបទេ។

កៈ អត់សូវជួប។

ខៈ យូរៗជួបម្តង។

កៈ បើសិនជាជួបនិយាយរំលឹករឿងនៅពីក្មេង។

ខៈ ជួបរំលឹក។

កៈ គាត់ខឹង?

ខៈ ថាអញបានចេះតែអក្សរតែអញចាញ់ង៉ែងបន្តិចវ៉ែ។

កៈ មើលទៅគាត់កាចដែរដូចរាងនេះដែរ។

ខ៖ កាច។

ក៖ ហើយអើរ...ពួកគាត់អត់ឧស្សាហ៍មកលេងអ៊ុំទៀតទេហី?

ខ៖ វាមក វាមកដែរតើតែវានៅខឹងឯងត្រឹមកាប៉ិចរឿងដី វាថាឯងត្រូវជើង។

ក៖ ត្រូវជើង?

ខ៖ ត្រូវជាមួយប្អូនវាត្រូវជើងដូចថាបញ្ចេះអញ្ចឹងទៅណាស់បញ្ចេះកុំឱ្យអញ្ចឹង ខឹងសម្លក់។

ក៖ គាត់ខឹងអ៊ុំរឿងអីគេទៅអ៊ុំ?

ខ៖ ខឹងរឿងដីហាំ។

ក៖ ចាស!

ខ៖ វាខឹងយើង ខឹងរឿងដីកាប៉ិចហ្នឹង។

ក៖ ថាខ្ញុំហ្នឹងចេះតែបញ្ចេះវាកុំឱ្យយកអញ្ចឹងហាំកុំឱ្យអញ្ចឹងទៅណាស់ មុនដំបូងវាប្រុងឱ្យមួយចំហៀង។

ក៖ ឱ្យទទេ?

ខ៖ វាយកទទេហ្នឹងណាស់កេរ្តិ៍ម៉ែៗចែក។ អញថាអើរ...ង៉ែងនៅតាំងពី៧៩(១៩៧៩)មកគ្មានអ្នកណាគេរកកេរ្តិ៍ទេព្រោះអីបើរដ្ឋនិយាយបើយើងចាប់បាននៅយើងនៅហើយព្រោះអីវា៤០ឆ្នាំហើយណាស់។

ក៖ ចាស!

ខ៖ អត់មានកេរ្តិ៍អីទៀតទេ មិនមែនដូចឥឡូវទេពីដើមមានកេរ្តិ៍ឱ្យចែកមានត្រឹមត្រូវយើងទៅនៅបាន។

ក៖ ចាសអានេះយើងដណ្តើមបានមក មិនមែនយាយគាត់អ្នកចែកឱ្យទេហេ?

ខ៖
អានេះដូចគាត់ចែកឱ្យដែរព្រោះអីដីកាលហ្នឹងវាកេរ្តិ៍មែនតែវានៅតាំងពី៧៩(១៩៧៩)មកគាត់មកនៅហ្នឹងរហូត។

ក៖ ចាស!

ខ៖
តែយើងលើកឧទាហរហ៍អញ្ចេះណាស់ថាដីហ្នឹងបើដូចថាហ្អែងនៅទីណាហើយគឺនៅទីហ្នឹងចេញអញ្ចឹង ហើយវាចេញទៅបាត់យូរអញ្ចឹងអាហ្នឹងបានគេហើយអ្នកនៅគេបានហើយអ្នកចេញទោះបីគេបានអីក៏ដោយព្រោះអីវា៤០ឆ្នាំហើយ។

ក៖ អ៊ុំតាំងពីក្មេងមកមានចូលចិត្តចម្រៀងអីអត់អ៊ុំ?ផ្នែកចម្រៀង?

ខ៖ អត់សូវចូលចិត្តទេអូន។

ក៖ ហើយ...?

ខ៖ អើរ...ចូលចិត្តដែរដូចព្រាប សុវត្ថិអីគាត់ច្រៀងចូលចិត្តអី អៀង ស៊ីធុលអីគាត់ទៅច្រៀងភ្លេងការអីណាស់ ម៉េង ពេជ្ជ ចិន្តាអីចូលចិត្ត។

ក៖ តែអ៊ុំចេះច្រៀងអត់អ៊ុំ?

ខ៖ អត់សូវទេអូនអើយ។

ក៖ ចាសអ៊ុំឥឡូវអត់មានគិតចង់ប្រកបមុខរបរអីផ្សេងទៀតណាអ៊ុំហេ?

ខ៖ អត់ទេអូន។

ក៖ កូននៅក្នុងបន្ទុកនៅសល់ប៉ុន្មាននាក់អ៊ុំ?នៅផ្ទះជុំគ្នាហាំ?

ខ៖ នៅជុំគ្នា៥។

ក៖ ៥នាក់នៅច្រើនដែរ។

ខ៖ តែអាយុចង់៤០រៀងៗខ្លួនតែវាអត់ព្រមយកប្រពន្ធ។

ក៖ ចុះអ៊ុំនៅក្នុងគ្រួសារអ៊ុំមានអ្នកណាចេះលេងឧបករណ៍ភ្លេងខ្មែរអីអត់?

ខ៖ អត់ ចេះតែកាត់សក់។

ក៖ ចេះតែកាត់សក់?

ខ៖ វាទើបរៀន រៀនយ៉ាងម៉េចដុងយ៉ាងម៉េចខ្ញុំអត់យល់។

ក៖ ចេះតែរៀនទៅ យូរៗចេះហើយ។

ឃ៖ ខ្ញុំរៀនទ្រ។

ក៖ រៀនទ្រ?

ឃ៖ បាទ!

ក៖ អ្នកណាអ្នករៀន?

ខ៖ មួយនិយាយមិញ កង់ជាមួយឪពុកមិញ និយាយអត់សូវត្រូវគ្នាទេ។

គ៖ លាភីវាទៅការហើយវាសើចដាក់ឯង ឯងចេះតែសើចដាក់វិញទៅ។

ក៖ អត់ចាំមុខចុះអ៊ុំដូចថាអ៊ុំប្រុសអីគាត់ចេះសង់ផ្ទះអីអត់អ៊ុំ?

ខ៖ អត់ អត់ចេះតែអូន។

ក៖ គាត់ចេះតតែធ្វើស្រែហ្នឹង?

ខ៖ គាត់ចេះតែធ្វើស្រែហើយនឹងឃ្វាលគោនាយអាយហ្នឹងអូន។

ក៖ អត់មានជំនាញអីផ្សេងៗ?

ខ៖ អត់ទេពេលមុនមកជំនាញរត់ម៉ូតូឌុប កាលពេលឆ្នាំ៨0ជាងនោះកាលពេលកូននៅតូចៗ។

ក៖ ចុះអ៊ុំមានជំនាញអីមួយខ្លួនឯងដែលចង់បន្តទុកឱ្យកូនចៅក្រោយៗអីទៀតទេអ៊ុំ?

ខ៖ មានតែឱ្យវារៀនតែខ្លួនវាហ្នឹង។

កៈ ចាសអត់ចង់បង្រៀនបង្ហាត់ធ្វើនំអី ដូចថាអ៊ុំពូកែធ្វើនំអញ្ចឹងហា៎?

ខៈ បង្ហាត់អីវាអត់ព្រមរៀនផងហ្នឹង។

កៈ អត់ព្រមរៀន គេចង់ធ្វើការងារខ្លួនគេ។

ខៈ ចាស!

កៈ ចុះអ៊ុំតាំងពីតូចមកអ៊ុំជួបផលលំបាកអីគេខ្លះដូចថា...?

ខៈ មានអីអូនអើយ...ដូចថាយើងពិបាកនៅជាមួយមីងមាជួយធ្វើការគាត់តិចតួចហ្នឹងណាស់។

កៈ ចាសមានតែប៉ុណ្ណឹង ដូចថាអត់មានការលំបាកអីធ្ងន់ធ្ងរអី?

ខៈ អត់ទេ គ្រាន់តែនៅជាមួយគាត់ ចេះតែជួយធ្វើគាត់អញ្ចឹងទៅ។

កៈ ចាសចុះអាពតអីអត់ដែលមានធ្វើបាបអីគម្រាមសម្លាប់ចង់អី?

ខៈ គម្រាមអញ្ចឹងដែរ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច។

កៈ
តែអត់អីដែរអ៊ុំណេះ?អ៊ុំមានបទពិសោធន៍អីដូចថាតាំងពីនៅក្មេងអ៊ុំមានបទពិសោធន៍អីល្អៗអញ្ចឹងធ្លាប់ជួបប្រទះអី?

ខៈ អត់មានអីអូន ដូចជាអត់!។

កៈ ចាស!

ខៈ មានតែជួបគេល្អហ្នឹងណាស់ ដូចថាយើងលក់ដីទិញដីអីមានគេដូចថាគេប្រដៅយើងអញ្ចឹងទៅណាស់។

កៈ ចាស!

ខៈ ដូចថាកុំឱ្យចាញ់បោកគេអញ្ចឹងទៅ។

កៈ អ៊ុំមានដីច្រើនកន្លែងដែរអ៊ុំណោះ?

ខ៖ អូនអើយខ្ញុំលក់ចែកកូនអស់ហើយ។

ក៖ ចាស!

ខ៖ ខ្ញុំលក់ខ្ញុំទិញដីវិញឱ្យកូន។

ក៖ ចាស!

ខ៖ ដីខ្ញុំវាច្រើនដែរ ២ ៣ហិចតា តែលក់ទៅទិញដីឡូត៍ឱ្យវាណាស់។

ក៖ ចាសចុះសុខភាពអ៊ុំខ្លួនឯងអីឥឡូវអត់អីណាហី?

ខ៖ អត់អីអូនសុខភាពអ៊ុំហ្នឹង...។

ក៖
ចាសអញ្ចឹងអ៊ុំមានអីចង់ផ្ដាំផ្ញើរទៅកូនចៅអ៊ុំដូចថានៅពេលដែលពួកគាត់ចង់ដឹងពីប្រវត្តិរបស់អ៊ុំអញ្ចឹងដែលគេស្រាវជ្រាវក្នុងអ៊ីនធើណេតអញ្ចឹងហា៎
ហើយវដូចថាចង់ផ្ដាំផ្ញើរអីទៅគេដូចថាខំធ្វើអីមួយឬក៏អត្តចរិកម៉េចអីម៉េចអញ្ចឹងទៅណាស់?

គ៖ ប្រដែរប្រដៅកូនចៅកុំឱ្យជក់គ្រឿងញៀន។

ខ៖ ចង់ផ្ដាំផ្ញើរដែរអូន។

ក៖ ចាស!

ខ៖ កុំឱ្យកូនជក់គ្រឿងញៀន ផឹកស៊ីស្រវឹងអី លេងល្បែងអីហ្នឹងណាស់។

ក៖ ចាស!

ខ៖ ចង់ផ្ដាំមិនឱ្យមានណាស់។

ក៖ ចាស!

ខ៖ មិនឱ្យរៀនសូត្រពីរបរហ្នឹងណាស់ ពីល្បែងហ្នឹង។

ក៖ ចាស!

ខ៖ ចង់ឱ្យវាមានការងារអីពិតប្រាកដកុំឱ្យយកគ្រឿងញៀនយកដាក់ខ្លួនហ្នឹងណាស់។

ក៖ ចាសសូមអរគុណអ៊ុំដែលឱ្យខ្ញុំបានសម្ភាសអ៊ុំនៅក្នុងថ្ងៃនេះ ការសម្ភាសហ្នឹងគេយកដាក់នៅក្នុងកម្មវិធីរបស់សាលាគេហៅថាសាលាប៊ី វ៉ាយ យូ សហរដ្ឋអាមេរិច។

ខ៖ ចាស!

ក៖ ហើយគេបញ្ចូលទៅក្នុងអ៊ីនធើណេតទៅហើយនៅពេលដែលកូនចៅអ៊ុំជំនាន់ក្រោយចង់ស្ដាប់សម្លេងអ៊ុំ ឬក៏ចង់ឃើញរូបរបស់អ៊ុំអញ្ចឹងគេអាចចូលក្នុងអ៊ីនធើណេតចូលក្នុងវេបសាយរបស់គេហ្នឹងគេអាចឃើញសម្លេងរបស់អ៊ុំហើយអើរ...សូមអរគុណអ៊ុំហើយសូមជំរាបលាអ៊ុំ៕